# ការពិតអំពីថ្នាំបង្ការជំងឺ COVID-19




## ហេតុអ្វីគួរចាក់ថ្នាំបង្ការ?

- ថ្នាំបង្ការជំងឺ COVID-19 គឺ**មានសុវត្ថិភាព និងមានប្រសិទ្ធភាព។**
- ការទទួលចាក់ថ្នាំបង្ការគឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីជួយការពារអ្នកនិងមនុស្សជាទីស្រឡាញ់របស់អ្នក ពីការធ្លាក់ខ្លួនឈឺ មិនបានទៅធ្វើការងារ ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់បាន។
- ថ្នាំបង្ការការពារប្រឆាំងមេរោគប្រភេទ Delta ផ្សេងៗ។ ហើយពួកវាក៏នឹងកាត់បន្ថយឱកាសដែលមេរោគប្រភេទថ្មីៗនិងដែលកាន់តែគ្រោះថ្នាក់ កុំឱ្យលេចឡើងផងដែរ។




## តើអ្នកណាខ្លះអាចទទួលថ្នាំបង្ការបាន?

### មនុស្សគ្រប់គ្នាដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ

- ថ្នាំបង្ការគឺ**ឥតគិតថ្លៃ**សម្រាប់មនុស្សគ្រប់គ្នា - ទោះបីជាអ្នកមិនមានការធានារ៉ាប់រងក៏ដោយ។
- អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។
- មនុស្សគ្រប់រូបមានអាយុចាប់ពី 12 ឆ្នាំឡើងទៅត្រូវបានណែនាំឱ្យចាក់ថ្នាំបង្ការ រួមទាំងអ្នកដែលមានផ្ទៃពោះ ឬបំបៅដោះកូន និងអ្នកដែលធ្លាប់មានជំងឺ COVID-19 ផងដែរ។
- មនុស្សភាគច្រើនដែលមានប្រតិកម្ម ឬការទាស់ ក៏អាចចាក់ថ្នាំបង្ការបានដែរ។



## របៀបទទួលថ្នាំបង្ការ

មានទីតាំងចាក់ថ្នាំបង្ការរាប់រយកន្លែងនៅទូទាំងខោនធី LA - ទីតាំងជាច្រើនបើកបម្រើការជូននៅចុងសប្ដាហ៍ និងពេលល្ងាច ហើយមិនបាច់ធ្វើការណាត់ជួបទេ។
ដើម្បីស្វែងរកទីតាំងនៅម្ដុំជិតអ្នក៖

- សូមចូលទៅកាន់គេហទំព័រ **VaccinateLACounty.com** ឬទូរស័ព្ទទៅលេខ **833-540-0473**, ចាប់ពី ម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ដែលមានព័ត៌មានជាច្រើនភាសាដែលបម្រើការជូន 24 ម៉ោងក្នុងមួយសប្ដាហ៍ (24/7) ឬសួរគ្រូពេទ្យ ឬឱសថការី (អ្នកលក់ថ្នាំពេទ្យ) ក្នុងតំបន់របស់អ្នកក៏បាន។
- ការដឹកជញ្ជូនដោយឥតគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្ដល់ជូនផងដែរ។

អនីតិជន (ជនមិនទាន់គ្រប់អាយុ) ត្រូវការការយល់ព្រមពីឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់ដើម្បីទទួលបានការចាក់ថ្នាំបង្ការ។

## តើថ្នាំបង្ការប្រភេទណាខ្លះ ដែលមានផ្ដល់ជូននៅសហរដ្ឋអាមេរិក?

| | Pfizer | Moderna | Johnson & Johnson |
|---|---|---|---|
| **មានសម្រាប់៖** | មនុស្សអាយុ 12 ឆ្នាំឡើងទៅ | មនុស្សអាយុ 18 ឆ្នាំឡើងទៅ | មនុស្សអាយុ 18 ឆ្នាំឡើងទៅ |
| **ផ្ដល់ជូនជា៖** | 2 ដូស - គម្លាត 21 ថ្ងៃ | 2 ដូស - គម្លាត 28 ថ្ងៃ | 1 ដូស |

ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយមធ្យម ឬធ្ងន់ធ្ងរ អ្នកប្រហែលជាត្រូវការចាក់ថ្នាំបង្ការដូសបន្ថែម - សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក។

VaccinateLACounty.com
(Cambodian)

County of Los Angeles Public Health
8-19-21

# ការពិតអំពីថ្នាំបង្ការជំងឺ COVID-19

## តើមានផលប៉ះពាល់អ្វីខ្លះ?



- ផលប៉ះពាល់របស់ថ្នាំបង្ការគឺអាចកើតមានជាទូទៅ និងអាចមានដូចជាឈឺដើមដៃ ឬ ដើមដៃឡើងក្រហម មានអារម្មណ៍អស់កម្លាំង គ្រុនក្តៅ គ្រុនរងា ឈឺក្បាល ឬឈឺសាច់ដុំ។ ទាំងនេះមិនមានន័យថាអ្នកមានជំងឺ COVID-19 នោះទេ។ មិនមែនមនុស្សគ្រប់គ្នានឹងមានផលប៉ះពាល់ទាំងនេះទេ។
- ផលប៉ះពាល់គឺជាសញ្ញាដែលថាប្រព័ន្ធភាពស៊ាំរបស់អ្នកកំពុង **បង្កើតការការពារ។** វាអាចប៉ះពាល់ដល់សមត្ថភាពរបស់អ្នក ក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃមួយចំនួន ប៉ុន្តែគួរតែបាត់ទៅវិញក្នុងរយៈពេលមួយ ឬពីរថ្ងៃបន្ទាប់ពីចាក់ថ្នាំបង្ការ។
- ផលប៉ះពាល់បែបធ្ងន់ធ្ងរគឺកម្រណាស់ ហើយភាគច្រើនក៏អាចព្យាបាលឱ្យជាសះស្បើយបានដែរ។





## ចុះសុវត្ថិភាពវិញ តើយ៉ាងម៉េចដែរ?

- អ្នកមិនអាចកើតជំងឺ COVID-19 ពីថ្នាំបង្ការឡើយ។ គ្មានថ្នាំបង្ការណាមួយមានផ្ទុកមេរោគដែលបង្កជំងឺ COVID-19 នោះទេ។
- ថ្នាំបង្ការត្រូវបានធ្វើតេស្តលើមនុស្សរាប់ម៉ឺននាក់ រួមទាំងមនុស្សដែលមានពណ៌សម្បុរស្បែកខុសគ្នា មនុស្សចាស់ និងមនុស្សដែលមានបញ្ហាសុខភាព ហើយត្រូវបានរកឃើញថាមានសុវត្ថិភាព។
- គ្រប់ជំហានទាំងអស់ ដែលត្រូវការចាំបាច់ដើម្បីប្រាកដថាថ្នាំបង្ការមួយ **មានសុវត្ថិភាព និងមានប្រសិទ្ធភាព** ត្រូវបានអនុវត្តតាម។
- ចាប់តាំងពីខែធ្នូ ឆ្នាំ 2020 **មនុស្សរាប់លាននាក់**បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 **ដោយសុវត្ថិភាព**។
- មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាការចាក់ថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាការបង្កកំណើតចំពោះបុរស និងស្ត្រីឡើយ។ ព័ត៌មានទាំងអស់ដែលយើងមានស្តីពីការមានផ្ទៃពោះ គឺគួរឱ្យទុកចិត្តបាន។ អ្នកវិទ្យាសាស្ត្របន្តសិក្សាលើថ្នាំបង្ការជំងឺ COVID-19 យ៉ាងយកចិត្តទុកដាក់ ដើម្បីស្វែងរកបញ្ហាទាក់ទងនឹងសុវត្ថិភាព និងចែករំលែកអ្វីដែលពួកគេរកឃើញ។

## បន្ទាប់ពីចាក់ថ្នាំបង្ការ

- អ្នកមិនត្រូវបាន **ចាក់ថ្នាំបង្ការពេញលេញ** នៅឡើយរហូតដល់រយៈពេល 2 សប្តាហ៍បន្ទាប់ពីអ្នកទទួលថ្នាំបង្ការប្រភេទ Johnson & Johnson ទីមួយ ឬថ្នាំបង្ការប្រភេទ Pfizer ឬ Moderna លើកទីពីររបស់អ្នក។ វាត្រូវការពេលវេលាដើម្បីឲ្យរាងកាយរបស់អ្នកបង្កើតភាពស៊ាំ។
- បន្ទាប់ពីអ្នកបានចាក់ថ្នាំបង្ការពេញលេញ បន្តចាត់វិធានការដើម្បីការពារខ្លួនអ្នក និងអ្នកដទៃ៖
  - **ពាក់ម៉ាស់ដែលបិទជិតល្អត្រឹមត្រូវ**
  - នៅតែផ្ទះ ពេលឈឺ
  - លាងសម្អាតដៃឱ្យបានញឹកញាប់
  - ជៀសវាងទីកន្លែងដែលមានមនុស្សច្រើនកុះករ ឬទីកន្លែងដែលមានខ្យល់បក់ចេញចូលមិនល្អ
  - រក្សាគម្លាតរបស់អ្នក







VaccinateLACounty.com
(Cambodian)

County of Los Angeles Public Health
8-19-21